# ជំងឺ COVID-19៖ ការពិតនៃថ្នាំបង្ការ
# ការមានកូន និងការមករដូវ



## ជំងឺ COVID-19 និងការមានកូន

- **មិនមានភស្តុតាងណាមួយ**ដែលបញ្ជាក់ថាថ្នាំបង្ការណាក៏ដោយ រួមទាំងថ្នាំបង្ការជំងឺ COVID-19 បណ្តាលឱ្យមានបញ្ហាមានកូនចំពោះស្ត្រី ឬបុរសនោះទេ។ តាមការពិត ការសិក្សានានាបង្ហាញថាមនុស្សដែលបានទទួលចាក់ថ្នាំបង្ការអាចមានអត្រាមានផ្ទៃពោះ ដូចគ្នាទៅនឹងមនុស្សដែលមិនបានចាក់ថ្នាំបង្ការដែរ។ មិនមានភស្តុតាងណាមួយដែលបញ្ជាក់ថាថ្នាំបង្ការជំងឺ COVID-19 ប៉ះពាល់ដល់ភាពពេញវ័យ ឬការលូតលាស់របស់មនុស្សវ័យជំទង់ឡើយ។




- អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ **ណែនាំឱ្យទទួលចាក់ថ្នាំបង្ការជំងឺ COVID-19** សម្រាប់អ្នកដែលចង់មានកូននាពេលអនាគត ក៏ដូចជាសម្រាប់អ្នកដែលកំពុងមានផ្ទៃពោះផងដែរ។
- អ្នកជំនាញទាំងឡាយក៏បានណែនាំផងដែរថា មនុស្សគ្រប់រូប **គួរតែធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 របស់ពួកគេ គ្រប់លក្ខណៈនិងទាន់ពេលវេលា**។ នេះមានសារៈសំខាន់ជាពិសេសសម្រាប់អ្នកដែលកំពុងព្យាយាមមានផ្ទៃពោះ ឬមានផ្ទៃពោះរួចហើយ។ ជំងឺ COVID-19 អាចបង្កស្ថានភាពកាន់តែមិនល្អ ក្នុងពេលមានផ្ទៃពោះ។ ការឆ្លងជំងឺ COVID-19 ក្នុងពេលមានផ្ទៃពោះ បង្កើនហានិភ័យនៃផលវិបាកសម្រាប់អ្នកមានផ្ទៃពោះ ក៏ដូចជាទារករបស់ពួកគេដែលកំពុងលូតលាស់ផងដែរ។

## ផលប៉ះពាល់បណ្តោះអាសន្ននៃថ្នាំបង្ការ ចំពោះការមករដូវ



- ស្ត្រីមួយចំនួនបានរាយការណ៍អំពីការផ្លាស់ប្តូររដូវរបស់ពួកគេ បន្ទាប់ពីទទួលចាក់ថ្នាំបង្ការជំងឺ COVID-19។ មានការស្រាវជ្រាវតិចតួចណាស់ទៅលើបញ្ហានេះ ប៉ុន្តែការសិក្សាថ្មីៗចំនួនពីរ បានបង្ហាញអំពីការប្រែប្រួលជាធម្មតា ប៉ុន្តែបន្តិចបន្តួច បន្ទាប់ពីទទួលចាក់ថ្នាំបង្ការជំងឺ COVID-19។ ទាំងនេះរួមមានទាំងការផ្លាស់ប្តូរនៃរយៈពេលវដ្តរដូវ និងពេលវេលារវាងការមករដូវ ក៏ដូចជាការធ្លាក់ឈាមច្រើនជាងធម្មតា។ **ការផ្លាស់ប្តូរ**ទាំងនេះ**គឺបណ្តោះអាសន្នតែប៉ុណ្ណោះ**។
- វាជាការសំខាន់ដែលត្រូវចងចាំថា ចំណុចជាច្រើនអាចបណ្តាលឱ្យមានការផ្លាស់ប្តូរវដ្តរដូវ ហើយការមករដូវមិនទៀងទាត់ គឺជារឿងធម្មតាណាស់ក្នុងចំណោមយុវវ័យ។ ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីការមករដូវរបស់អ្នក សូមពិភាក្សាជាមួយគ្រូពេទ្យ។



សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ [ថ្នាំបង្ការជំងឺ COVID-19 សម្រាប់មនុស្សដែលចង់មានកូន] របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។

### ថ្នាំបង្ការគឺឥតគិតថ្លៃសម្រាប់មនុស្សគ្រប់គ្នា - បើទោះបីជាអ្នកមិនមានធានារ៉ាប់រងក៏ដោយ

អ្នកនឹងមិនត្រូវបានសួរនាំអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។ មានទីតាំងចាក់ថ្នាំបង្ការជាច្រើនកន្លែងនៅទូទាំងខោនធី LA - ដែលទីតាំងជាច្រើនបើកបម្រើការជូននៅចុងសប្តាហ៍និងពេលល្ងាច ហើយមិនចាំបាច់ធ្វើការណាត់ជួបទេ។ ដើម្បីស្វែងរកទីតាំងនៅក្នុងតំបន់របស់អ្នក៖

- សូមចូលទៅកាន់គេហទំព័រ VaccinateLACounty.com ឬទូរស័ព្ទទៅលេខ **833-540-0473** បម្រើការជូនចាប់ពីម៉ោង 8:00 ព្រឹកដល់ម៉ោង 8:30 យប់។
- អ្នកក៏អាចទូរស័ព្ទទៅលេខ 2-1-1 ឬសាកសួរគ្រូពេទ្យ ឬឱសថការីក្នុងតំបន់របស់អ្នកបានផងដែរ។
- ការដឹកជញ្ជូនដោយឥតគិតថ្លៃ និងការចាក់ថ្នាំបង្ការនៅតាមផ្ទះក៏មានផ្តល់ជូនផងដែរ។